THE SCHOOL DISTRICT OF PHILADELPHIA

**ការិយាល័យកម្មវិធីរបស់សហព័ន្ធ**
ជាន់ទី ៣ ច្រក D
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០២០

ជូនចំពោះ មាតាបិតា/អាណាព្យាបាល ជាទីគោរព៖

ក្នុងនាមជា មាតាបិតា ឬ អាណាព្យាបាល របស់សិស្សដែលរៀននៅសាលាដែលទទួលប្រាក់ របស់ច្បាប់ Title I របស់សហព័ន្ធ លោកអ្នកមានសិទ្ធិដឹងពីសមត្ថភាពជំនាញរបស់ គ្រូ និង អ្នកអប់រំ ដែលបង្រៀនកូនរបស់លោកអ្នក។

ច្បាប់សហព័ន្ធតម្រូវឱ្យក្រសួងអប់រំដែលទទួលប្រាក់ជំនួយរបស់ច្បាប់ Title I គោរពតាម និង ផ្តល់ជូនលោកអ្នកនូវព័ត៌មានដែលលោកអ្នកបានស្នើសុំ ឱ្យទាន់ពេលវេលា។ សាលាទាំងអស់មានបញ្ជីបញ្ជាក់ពីសមត្ថភាពរបស់ គ្រូ និង អ្នកអប់រំ របស់ខ្លួន។ នៅពេលណាកដោយ លោកអ្នកអាចសួរ៖

- ថាតើគ្រូមាន លក្ខណៈសម្បត្តិទៅតាមការតម្រូវរបស់រដ្ឋ និង វិញ្ញាបនប័ត្រដែលគេតម្រូវទៅតាម កម្រិតថ្នាក់ និង មុខវិជ្ជាដែលគាត់កំពុងបង្រៀន ឬ អត់។
- ថាតើគ្រូបានទទួលវិញ្ញាបនប័ត្រ បន្ទាន់ ឬ តាមលក្ខណៈពិសេស ដែលការតម្រូវរបស់រដ្ឋត្រូវបានគេលើកលែង និង
- ថាតើសញ្ញាប័ត្រ បរិញ្ញា ឬ អនុបណ្ឌិត ឬ បណ្ឌិត ដែលគ្រូមាន រួមទាំង វិញ្ញាបនប័ត្រនៃការបញ្ចប់ការសិក្សា និង សញ្ញាប័ត្រអ្វីផ្សេងទៀត និង ជំនាញ ឬ មុខវិជ្ជាសិក្សា។
- ថាតើកូនរបស់លោកអ្នកបានទទួលជំនួយពីអ្នកអប់រំឬអ្វី បើទទួល សមត្ថភាពរបស់គាត់។

ច្បាប់ស្តីពីសិស្សម្នាក់ៗត្រូវទទួលជោគជ័យ (ESSA) ដែលត្រូវបានគេដាក់បញ្ចូលជាធរមាន នៅខែធ្នូ ឆ្នាំ ២០១៥ រួមទាំងការស្នើសុំសិទ្ធិនៃការត្រូវយល់ដឹង។ គ្រប់ពេល លោកអ្នកអាចស្នើសុំ៖

- ព័ត៌មានអំពីច្បាប់ដែលទាក់ទងនឹងការចូលរួមរបស់សិស្សក្នុងការវាយតម្លៃ និង នីតិវិធីនៃការបដិសេធមិនចូលរួម និង
- ព័ត៌មានស្តីពីការវាយតម្លៃដែលគេតម្រូវ រួមមាន៖
    - មុខវិជ្ជានៃការប្រឡង
    - គោលបំណងនៃការប្រឡង
    - ព័ត៌មាននៃការតម្រូវ (បើសិនជាមាន)
    - រយៈពេលដែលសិស្សត្រូវចំណាយលើការប្រឡង និង
    - ពេលវេលា និង ទម្រង់ នៃការចែកចាយលទ្ធផល។

ព័ត៌មានទាំងអស់ខាងលើ លោកអ្នកអាចស្នើសុំតាមរយៈនាយកសាលារបស់លោកអ្នក។

បុគ្គលិករបស់យើងប្តេជ្ញាជួយកូនរបស់លោកអ្នកបង្កើននូវចំណេះដឹង ដែលគាត់ត្រូវការដើម្បីទទួលបានជោគជ័យនៅ សាលា និង ទៅអនាគត។ ការប្តេជ្ញាចិត្តនោះរួមបញ្ចូលទាំងការធ្វើយ៉ាងណាឱ្យ គ្រូ និង អ្នកអប់រំ របស់យើងទាំអអស់ បំពេញបានតាមការតម្រូវរបស់រដ្ឋ ផិនស៊ីលវេនីញ៉ា។ យើងទន្ទឹងរង់ចាំឆ្នាំសិក្សាខាងមុខនេះ ហើយជាមួយគ្នា យើងនឹងធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់កូនលោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

______________________________

Ashley Glasgow-Crockett
អនុប្រធាន ការិយាល័យកម្មវិធីរបស់សហព័ន្ធ